**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ: ០០៣ សរ.សខ

# សារាចរ

## ស្តីពី

## វិធានការហាមការជក់និងការបង្អួយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការនិងកន្លែងសាធារណៈ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០១០៦/០០២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់និងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ បានណែនាំឲ្យក្រសួងសុខាភិបាល ចេញនូវសារាចរស្តីពីវិធានការហាមការជក់និងការបង្អុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការនិងកន្លែងសាធារណៈ។

ដើម្បីចូលរួមក្នុងការការពារសុខុមាលភាពរបស់ប្រជាជន ការពារនិងទប់ស្កាត់ការរងផ្សែងផលិតផលថ្នាំជក់ដែលបង្កឲ្យមានហានិភ័យសុខភាពអ្នកនៅជុំវិញ និងបរិស្ថាននិងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ ក្រសួងសុខាភិបាលសូមដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖

១. ការជក់ ឬការបង្អុយផ្សែងផលិតផលថ្នាំជក់នៅតាមកន្លែងធ្វើការ គ្រឹះស្ថានឧត្តមសិក្សា កន្លែងសាធារណៈ កន្លែងអគារសាធារណៈចំហ កន្លែងអគារសាធារណៈបិទជិត មធ្យោបាយដឹកជញ្ជូនសាធារណៈ ត្រូវហាមឃាត់។ ត្រូវបានចាត់ទុកថាផលិតផលថ្នាំជក់ គឺជាផលិតផលគ្រប់ប្រភេទផ្សំឡើង ពីសន្លឹកថ្នាំជក់ សរសៃថ្នាំជក់ ឬសារធាតុនៃថ្នាំជក់ ដែលផលិតដោយឧស្សាហកម្មថ្នាំជក់និងមធ្យោបាយផ្សេងៗទៀត ប្រើប្រាស់សម្រាប់ជក់ដោយផ្ទាល់ ឬដោយទម្រង់ផ្សេងៗទៀតរួមមាន ជញ្ជក់ ទំពារ ចុក ឬហិត ជាអាទិ៍។

ការជក់ សំដៅដល់ការប្រើប្រាស់ផលិតផលថ្នាំជក់ដែលកំពុងឆេះ ទោះបីជាផ្សែង ឬចំហាយនោះត្រូវបានស្រូបចូល ឬបញ្ចេញមកក្រៅក្តី។

កន្លែងធ្វើការ សំដៅដល់កន្លែងដែលជនណាម្នាក់បម្រើការងារជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នក្នុងអគារ ទោះជាការងារនោះទទួលបានប្រាក់កម្រៃ ឬមិនយកកម្រៃ ដោយស្ម័គ្រចិត្ត ឬកាតព្វកិច្ចក្តី ក្នុងនោះរួមបញ្ចូលទាំងការិយាល័យផ្ទាល់ខ្លួន កន្លែងរួម និងកន្លែងផ្សេងទៀត/..

ដែលជាទូទៅ កន្លែងនោះត្រូវបានប្រើប្រាស់ ឬចេញចូលក្នុងអំឡុងពេលបំពេញការងារ។ ក្នុងអគារនៅទីនេះសំដៅដល់ក្នុងទីចំហ ក្នុងបន្ទប់ដែលមានដំបូលនិងព័ទ្ធដោយជញ្ជាំងមួយ ឬច្រើនដោយមិនគិតពីប្រភេទសំភារៈដែលប្រើប្រាស់សម្រាប់ធ្វើជាដំបូលឬជញ្ជាំង និងដោយមិនគិតថាហេដ្ឋារចនាសម្ព័ន្ធនេះប្រើជាប្រចាំឬបណ្តោះអាសន្នឡើយ។

កន្លែងសាធារណៈ សំដៅដល់កន្លែងអគារសាធារណៈចំហ កន្លែងអគារសាធារណៈបិទជិត មធ្យោបាយដឹកជញ្ជូនសាធារណៈ ដែលសាធារណជនអាចចេញចូលឬប្រើប្រាស់ ។

មធ្យោបាយដឹកជញ្ជូនសាធារណៈ សំដៅដល់យានយន្តទាំងអស់ ដែលបានដឹកសាធារណជនទូទៅ ក្នុងគោលបំណងពាណិជ្ជកម្ម រួមបញ្ចូលទាំងរថយន្តឈ្នួល។

កន្លែងអគារសាធារណៈបិទជិត សំដៅដល់កន្លែងដែលមានដំបូល ជញ្ជាំង ទ្វារ និងបង្អួចបិទជិត ហើយដំណើរការសកម្មភាពដោយសារប្រព័ន្ធខ្យល់ខាងក្នុង ទោះបីជាពេលខ្លះ ទ្វារ ឬបង្អួចត្រូវបានបើកចំហក៏ដោយ។

កន្លែងអគារសាធារណៈចំហ សំដៅដល់កន្លែងដែលមានដំបូល ជញ្ជាំង ឬបាំងមួយ ឬច្រើន មានឬគ្មានទ្វារ ដោយមិនគិតពីប្រភេទសម្ភារៈដែលប្រើប្រាស់សម្រាប់ធ្វើជាដំបូល ជញ្ជាំង ឬរបាំងនិងដោយមិនគិតថា កន្លែងនោះត្រូវបានសង់ឬដំឡើង សម្រាប់ជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នឡើយ។

២. ការជក់ ឬ ការបង្ហុយផ្សែងផលិតផលថ្នាំជក់ក្នុងបរិវេណ គ្រឹះស្ថានសុខាភិបាល គ្រឹះស្ថានសិក្សា ទារកដ្ឋាន សួនកុមារ គ្រឹះស្ថានសាសនា សារមន្ទីរ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ ស្ថានីយប្រេងឥន្ធនៈ និងកន្លែងងាយឆាបឆេះ ត្រូវហាមឃាត់។

៣. អ្នកគ្រប់គ្រងឬម្ចាស់កន្លែងធ្វើការនិងអ្នកគ្រប់គ្រងឬម្ចាស់កន្លែងសាធារណៈ ត្រូវបិទផ្សាយឬដាក់បម្រាមអំពីការហាមការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅតាមផ្លូវចូលនិងកន្លែងសមស្របផ្សេងទៀត ដែលឱ្យសាធារណជនអាចមើលឃើញច្បាស់។

បម្រាមអំពីការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ត្រូវតែជាសារសរសេរជាលាយលក្ខណ៍អក្សរ និងរៀបចំជាសញ្ញាបង្ហាញអំពីការហាមឃាត់។ បម្រាមជាអក្សរត្រូវអមដោយសញ្ញាបម្រាម។ បម្រាមត្រូវសរសេរថា " ហាមជក់បារី " អមជាមួយនឹងសញ្ញាបម្រាមដែលមានរូបភាពបារីមួយដើម នៅក្នុងរង្វង់ក្រហម និងមានបន្ទាត់ក្រហមមួយគូសចំអង្កត់ផ្ចិតបញ្ឆៀងពីខាងលើនៃផ្នែកខាងឆ្វេង មកខាងក្រោមផ្នែកខាងស្តាំ ឬការបង្ហាញតាមរូបភាពផ្សេងទៀតដែលមានអត្ថន័យដូចគ្នា។ អត្ថបទត្រូវមានទំហំ៦០ភាគរយនៃសញ្ញា។

បម្រាមអំពីការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ត្រូវមានទទឹងនិង/ឬបណ្តោយអប្បរមា ២០សង់ទីម៉ែត្រ សម្រាប់ទីកន្លែងនានា និង១០សង់ទីម៉ែត្រ សម្រាប់មធ្យោបាយដឹកជញ្ជូន។

៤. នៅគ្រប់កន្លែងធ្វើការ កន្លែងសាធារណៈ និងកន្លែងផ្សេងៗទៀតដែលត្រូវបានហាមឃាត់មិនឲ្យជក់និងបង្ហុយផ្សែងផលិតផលថ្នាំជក់ មិនត្រូវដាក់តាំង ឬបង្ហាញប្រដាប់គោះបារី ឬរូបភាព ប្រដាប់គោះបារី ទោះជាក្នុងទំរង់ ទំហំ និងប្រភេទណាក៏ដោយ។៚

៥. អ្នកគ្រប់គ្រងឬម្ចាស់កន្លែងធ្វើការ អ្នកគ្រប់គ្រងឬម្ចាស់កន្លែងសាធារណៈ ត្រូវធ្វើការអប់រំណែនាំមិនឲ្យជក់ ចំពោះជនណាមិនអនុវត្តតាម បម្រាមនៃការហាមជក់ឬការបង្ហុយផ្សែង ផលិតផលថ្នាំជក់។
ក្នុងករណីមិនអនុវត្តតាមការណែនាំ អ្នកគ្រប់គ្រងឬម្ចាស់កន្លែងធ្វើការ អ្នកគ្រប់គ្រងឬម្ចាស់កន្លែងសាធារណៈ ត្រូវអញ្ជើញអ្នកជក់ ចេញក្រៅ។
ក្នុងករណីមិនអនុវត្តតាមការណែនាំ ឬការអញ្ជើញ ឬមិនរាងចាលអ្នកគ្រប់គ្រងឬម្ចាស់កន្លែងធ្វើការ អ្នកគ្រប់គ្រងឬម្ចាស់កន្លែងសាធារណៈ ត្រូវ ស្នើសុំទៅសមត្ថកិច្ច ដើម្បីធ្វើការអប់រំណែនាំ ឬអញ្ជើញអ្នកជក់ចេញក្រៅ។

៦. នៅតាមអាកាសយានដ្ឋានត្រូវមានបន្ទប់សម្រាប់ជក់ ឬបង្ហុយផ្សែងផលិតផលថ្នាំជក់ចំពោះភ្ញៀវរង់ចាំធ្វើដំណើរ។ នៅតាមភោជនីយដ្ឋាន អាចរៀបចំបែងចែកបន្ទប់សម្រាប់អ្នកជក់បារីដោយឡែក។ នៅតាមអាហារដ្ឋាន អាចរៀបចំបែងចែកតុសម្រាប់អ្នកជក់ដោយឡែកឆ្ងាយពីអ្នកមិនជក់។

៧. សូមគ្រប់ក្រសួង ស្ថាប័ន អ្នកគ្រប់គ្រងឬម្ចាស់កន្លែងធ្វើការ អ្នកគ្រប់គ្រងឬម្ចាស់កន្លែងសាធារណៈ និងសាលារាជធានី-ខេត្តចូលរួមសហការអនុវត្តសារាចរនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២ ខែ[illegible] ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

ម៉ម ប៊ុនហេង

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចចំណុចទី៧
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
-អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ